**Cambodian - Warts**

ជម្ងឺឆ្លង - វ៉ាយរឹស



# ឫស

## ចំណុចសំខាន់ៗ

- **ឫសជាជម្ងឺវ៉ាយរឹសនៅក្នុងស្បែក**
- **ចំនួនពីរភាគបីនៃឫសនឹងជាបាត់ទៅវិញក្នុងរយៈពេលពីរឆ្នាំ ដោយពុំចាំបាច់ព្យាបាលអ្វីឡើយ ហើយឥតមានទុកស្លាកស្នាមឡើយ**
- **ការព្យាបាលដែលមិនបណ្តាលឲ្យមានស្លាកស្នាម ដូចជាថ្នាំសម្លាប់ឫស គឺមានប្រសិទ្ធិភាពបំផុត**

## តើវាជាអ្វី?

ឫសគឺជាបញ្ហាកើតមានញឹកញយនៅក្នុងចំណោមកូនក្មេង ហើយបណ្តាលមកពីមេរោគវ៉ាយរឹស។ វាមិនសូវកើតមាននៅក្នុងចំណោមទារក និងកុមារភាពទេ ក៏ប៉ុន្តែវាលេចឲ្យឃើញយ៉ាងញឹកញាប់ កាលណាកូនក្មេងវាមានវ័យធំឡើង។

វាមានស្នាមពក ហើយមានពណ៌ស្បែកដែលមានមុខខាងលើសំបកគគ្រាត។ ទំហំ និងចំនួនរបស់វាគឺប្រែប្រួល ហើយឫសថ្មីច្រើនកើតនៅកន្លែងស្បែកដែលមានរបួស។ វាអាចកើតនៅលើស្បែកគ្រប់កន្លែង ក៏ប៉ុន្តែតាមធម្មតាវាតែងកើតនៅដៃ និងក្បាលជង្គង់នៅក្នុងចំណោមកូនក្មេង។ ឫសកើតនៅបាតជើងត្រូវបានគេហៅថា ឫសបាតជើង។ ឫសក៏អាចលេចឲ្យឃើញជាស្នាមដែលមានពណ៌ស្បែករាបស្មើតូចៗនៅលើខ្នងដៃ ឬលើមុខផងដែរ។

## តើវាឆ្លងដោយរបៀបណា?

ឫសគឺជាមេរោគវ៉ាយរឹសដែលមានវ៉ាយរឹសចូលទៅផ្នែកខាងលើស្បែក ជាពិសេសកន្លែងដែលមានរបួសស្រាប់។ វាអាចឆ្លងរាលដាលតាមរយៈការប៉ះពាល់ផ្ទាល់ ដោយប៉ះឫសរបស់ជនម្នាក់ទៀត ជាពិសេសប្រសិនបើស្បែកមានរបួស។ វាក៏អាចឆ្លងរាលដាលដោយប៉ះប្រយោលផងដែរ។ ជាញឹកញយ វ៉ាយរឹសតែងរស់នៅក្នុងកន្លែងសើមដូចជាជុំវិញអាងហែលទឹក ឬកំរាលបន្ទប់ទឹក ហើយអាចឆ្លងដោយសារការដើរជើងទទេរនៅលើទីកន្លែងទាំងនោះ។ ឫស្សអាចកើតមាននៅជុំវិញក្រចកកូនក្មេងដែលខាំក្រចករបស់ខ្លួន ឬនៅបបូរមាត់កូនក្មេងដែលបៀមជញ្ជក់ម្រាមដៃរបស់ខ្លួន។

## តើគេអាចការពារវាដោយរបៀបណា?

ការលាងសំអាតអាងងូតទឹកឲ្យបានស្អាតបន្ទាប់ពីបានប្រើរួច កុំឲ្យប្រើកន្សែងរួមគ្នា ហើយការគ្របឫសជើងនៅពេលហែលទឹក ឬងូតទឹក នឹងជួយកាត់បន្ថយកការឆ្លងរាលដាលឫស។ ការគ្របឫសជាមួយបន្ទះស្អិតបិទមុខរបួស អាចជួយបញ្ឈប់កូនក្មេងពីការខាំ ឬឆ្កឹះវា។

## តើគេអាចព្យាបាលវាដោយរបៀបណា?

យ៉ាងហោចណាស់ចំនួនពីរភាគបីនៃឫសនឹងជាបាត់ទៅវិញ ក្នុងរយៈពេលពីរឆ្នាំ ដោយពុំចាំបាច់ព្យាបាលអ្វីឡើយ ហើយឥតមានទុកស្លាកស្នាមឡើយ។ ដោយហេតុនេះ ការព្យាបាលឫសនីមួយៗមិនជាចាំបាច់អ្វីទេ។

ថ្នាំសម្លាប់ឫសដែលអាចទិញផ្ទាល់ពីឱសថស្ថាន គឺជាការចាប់ផ្តើមល្អ ក៏ប៉ុន្តែត្រូវការប្រើវាឲ្យបានទៀងទាត់ចំនួនពីរ ឬបីខែដើម្បីកំចាត់ឲ្យអស់ឫសនីមួយ។ ត្រាំឫសនៅក្នុងទឹកក្តៅមុននឹងប្រើថ្នាំសម្លាប់ឫស រួចហើយឆ្កឹះស្បែកងាប់នៅពីលើឫស ដើម្បីឲ្យថ្នាំសម្លាប់ឫសជ្រាបចូលទៅក្នុងឫស។

ប្រសិនបើឫសក្លាយទៅជាការឈឺចាប់ ឬនាំឲ្យព្រួយបារម្ភណ៍ការព្យាបាលពីវេជ្ជបណ្ឌិតអាចរាប់បញ្ចូលទាំងការធ្វើឲ្យត្រជាក់ខ្លាំងជាមួយ liquid nitrogen (វត្ថុរាវណាយត្រូជីន)។ ក៏ប៉ុន្តែនេះអាចទៅជាការឈឺចាប់ ហើយប្រហែលមិនមែនជាវិធីសមរម្យល្អសំរាប់កុមារតូចៗឡើយ។ ការអុជកាត់ចេញ ឬកោសឫសចេញជាការព្យាបាលមិនសូវមានគេប្រើសំរាប់កូនក្មេងឡើយ ហើយអាចបណ្តាលឲ្យមានស្លាកស្នាមយូរអង្វែង។

## ពត៌មានបន្ថែមទៀត

- គិលានុបដ្ឋាយិកាមើលថែទាំសុខភាពមាតា និងកុមារ
- ឱសថការីរបស់លោកអ្នក
- វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក
- វេជ្ជបណ្ឌិតឯកទេសជម្ងឺសើរស្បែក

© 2002, Department of Dermatology, St. Vincent’s Hospital Melbourne, Victoria Parade, Fitzroy, Victoria 3065 Australia.